# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ ឧសភា ឆ្នាំ ២០១៤
## និងទិសដៅការងារ ខែ មិថុនា ឆ្នាំ ២០១៤

(ពីថ្ងៃទី២៦/០៤/២០១៤ ដល់ ២៥/០៥/២០១៤)

ដោយផ្អែកលើផែនការសកម្មភាពអនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ត្រីមាសទី២ ឆ្នាំ២០១៤ និង ទិសដៅការងារ ដែលបានដាក់ចេញកាលពីខែមេសា ឆ្នាំ២០១៤ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋទទួលបានលទ្ធផលដូចខាងក្រោម ។

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាល និង កងរាជអាវុធហត្ថរាជធានី-ខេត្ត ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរ និងប្រើប្រាស់គ្រឿងញៀន បានកើតមាននៅ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, តាកែវ, កំពង់ស្ពឺ, កំពង់ចាម, រតនគិរី, បាត់ដំបង, កោះកុង, បន្ទាយមានជ័យ និង ខេត្តក្រចេះ ។ ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបបាន ក្នុងខែឧសភានេះ កត់សំគាល់ឃើញមាន ២ ករណីធំៗ ដែលបង្ក្រាបដោយ ៖

- មន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ១ ករណី ព្រមទាំងដកហូតមេតំហ្វេតាមីនក្រាមម្សៅ (ICE) ជាង ១ គីឡូក្រាម ។
- កងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ១ ករណី ព្រមទាំងដកហូតមេតំហ្វេតាមីនក្រាមម្សៅ ជិត ២ គីឡូក្រាម ។

ជាមួយនេះ មន្ទីរប្រឆាំងគ្រឿងញៀន បានធ្វើការបែងចែកបទល្មើសគ្រឿងញៀនទៅតាមតំបន់នីមួយៗ រួមមាន ៖ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញមាន ១៩ ករណី, ទិសខេត្តជាប់ព្រំដែនថៃមាន ១៣ ករណី, ទិសជាប់ព្រំដែនឡាវមាន ៣ ករណី និងទិសជាប់ព្រំដែនវៀតណាមមាន ០៧ ករណី ។

## II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. អំពីការងារដឹកនាំ

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ និងដឹកនាំបញ្ហាលើការងារជាគោលសំខាន់ៗ រួមមាន ៖

**ក- អំពីគោលការណ៍ណែនាំ និងដឹកនាំបញ្ហា**

- ត្រៀមរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១៤ ។
- ពិនិត្យ និងរៀបចំកែសម្រួលសមាសភាពអ្នកគ្រប់គ្រងមណ្ឌលបណ្តោះអាសន្ន សម្រាប់អប់រំ បន្សាបព្យាបាលអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ ។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងក្រសួងទេសចរណ៍ ដើម្បីអប់រំ បង្ការ ទប់ស្កាត់និងបង្ក្រាបឲ្យបានសកម្មថែមទៀតនូវផលិតផល ស៊ីហ្សា និង បារីអេឡិចត្រូនិច ។
- សិក្សាពីម៉ាស៊ីនវិភាគគ្រឿងញៀនដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីលើកគម្រោងស្នើសុំថវិកាទិញទៅរាជរដ្ឋាភិបាល ។
- ជំរុញក្រសួងសុខាភិបាល ក្នុងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមប៉ុស្តិ៍សុខភាពក្នុងពន្ធនាគារ ។
- បើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជំនាញ ដល់មន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិចាប់ពីថ្នាក់ខេត្ត រហូតដល់ ថ្នាក់ប៉ុស្តិ៍រដ្ឋបាលមូលដ្ឋាន ។

**ខ- អំពីលិខិតបទដ្ឋានគតិយុត្តិ**

- ជំរុញការរៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- សហការជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីកែសម្រួលខ្លឹមសារឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

### ២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

#### ២.១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែមេសា ឆ្នាំ២០១៤ កន្លងទៅ ក្រសួង-ស្ថាប័នជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ ខែ, ការអប់រំតាមសហគមន៍ និងការបណ្តុះបណ្តាលក្រុមជនបង្គោលទទួលបានលទ្ធផលគួរកត់សំគាល់ ដូចមានក្នុងឧបសម្ព័ន្ធទី១ ។

**ក្នុងនោះ** លទ្ធផលដែលបានអនុវត្តដោយ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមមាន ៖

- ផ្តល់ការគាំទ្រដល់សមាគមយុវជនខ្មែរ បន្តបើកវគ្គបណ្តុះបណ្តាល ការសម្តែងរឿងខ្លី ការចងក្រងក្លឹបយុវ-

ជន សកម្មភាពអប់រំរបស់ក្លឹបយុវជន ការចុះប្រមូលព័ត៌មាន/ទិន្នន័យ និងសិក្ខាសាលាស្តីពី " ការលើកកម្ពស់ការចូលរួមរបស់យុវជន ក្នុងការអប់រំបង្ការគ្រឿងញៀន និងគ្រឿងស្រវឹង" តាមវិទ្យាល័យ ឃុំ/សង្កាត់ នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប និង ខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ២០១៤ ។

- ផ្តល់ការគាំទ្រដល់សមាគមតន្ត្រីសំនៀងជនពិការ ដែលបានរៀបចំកម្មវិធីប្រគំតន្ត្រីសប្បុរសធម៌សម្រាប់ជនពិការភ្នែក (នៅខេត្តព្រះសីហនុ) ដោយបានបញ្ជ្រាប សារ អប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។
- រៀបចំកម្មវិធីសម្រាប់ប្រិយមិត្តអ្នកអាន សារ អប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមគេហទំព័រ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានប្រិយមិត្តអ្នកអានចំនួន ១៩៩.៩៩៧ ដង ។
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលជនបង្គោលសម្រាប់បណ្តាញការងារសហគមន៍ នៅក្នុងឃុំ ២ របស់ខេត្តកំពង់ចាម នាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៤ មានអ្នកចូលរួម **៨៩** រូប (កម្មវិធីរបស់អង្គការពន្លឺកុមារកម្ពុជា) ។
- ពិភាក្សាជាមួយប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកោះកុង ដើម្បីរៀបចំកម្មវិធីប្រឡងគូរគំនូរដណ្តើមប្រាក់រង្វាន់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (១៨-២០/៥/២០១៤) ។
- សហការជាមួយក្រសួងព័ត៌មាន រៀបចំសិក្ខាសាលាស្តីពីការបញ្ជ្រាបវិធានការ និងហានិភ័យក្នុងការសេពគ្រឿងញៀន ដែលមានសិក្ខាកាមជា អ្នកកាន់កម្មវិធីវិទ្យុ អ្នកសរសេរព័ត៌មានវិទ្យុ អ្នកសារព័ត៌មានទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី វិបសាយ និងនិស្សិតនៃសាកលវិទ្យាល័យអាស៊ី អឺរុប ចូលរួម **១៥០** នាក់ ។
- រៀបចំកិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួង-ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការងារផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ និងការកាត់បន្ថយតម្រូវការគ្រឿងញៀន ។
- សហការជាមួយអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីតន្ត្រីស្រុកស្រែចំនួនពីរលើក នៅខេត្តកំពង់ស្ពឺ (ថ្ងៃទី០៩/៥/២០១៤ មានមហាជនទស្សនាប្រមាណ **១៤.០០០** នាក់) នៅខេត្តកណ្តាល (ថ្ងៃទី១៥/៥/២០១៤ មានមហាជនទស្សនាប្រមាណ **១៨.០០០** នាក់)
- សហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះទៅផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅខេត្តស្វាយរៀង ដល់មន្ត្រីរាជការ ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស សរុប **៤០០** នាក់ (២៩/៥/២០១៤) ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅតាមសហគមន៍ និងការងារបណ្តុះបណ្តាលក្រុមជនបង្គោល ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន **៧** គឺ ខេត្តកណ្តាល, សៀមរាប, ពោធិ៍សាត់, កំពង់ចាម, ស្វាយរៀង, ព្រៃវែង និង ខេត្តក្រចេះ នៅក្នុងខែឧសភា ឆ្នាំ២០១៤ នេះ មានមហាជនចូលរួមប្រមាណ **១១៦.៣០៧** នាក់ លើ ១៦៣.៩១៥ នាក់ នៃខែមេសាឆ្នាំ២០១៤ ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១។

## ២.២. ***ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ក្នុងខែឧសភានេះ មន្ត្រីអនុវត្តន៍ច្បាប់បានបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

## ក. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន ដែលបង្ក្រាបបានសរុប ***៥៨ ករណី*** លើ ១០៣ ករណី នៃខែមេសា ឆ្នាំ២០១៤
- ជនសង្ស័យ ដែលបានឃាត់ខ្លួន សរុប ***១២០*** នាក់ លើ ២៣២ នាក់ នៃខែមេសា ឆ្នា២០១៤

  ក្នុងចំនួនបទល្មើសគ្រឿងញៀនទាំង ***៥៨ ករណី*** និង ជនសង្ស័យទាំង ***១២០ នាក់*** ខាងលើគឺ :

  - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយនគរបាល មាន ***៤២ ករណី***, ជនសង្ស័យ ***៧១ នាក់*** (ស្រី ១១ នាក់)
  - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយកងរាជអាវុធហត្ថ ***១៦ ករណី***, ជនសង្ស័យ ***៤៩ នាក់*** (ស្រី៣ នាក់)
- ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលបានឃាត់ខ្លួនទាំង ១២០ នាក់ ខាងលើ មាន ៣ សញ្ជាតិ គឺ ខ្មែរ ១១៤ នាក់ (ស្រី ១៤ នាក់), វៀតណាម ៥ នាក់ (ប្រុស), ឡាវ ១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។
- **វត្ថុតាងគ្រឿងញៀនចាប់យក រួមមាន** មេតំហ្វេតាមីន WY ៤៧៣,៦៧ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៣.២៤១,៨៥ ក្រាម, អ៊ិចស្តាស៊ី ២៣,៤៣ ក្រាម, កេតាមីន ១៧៨,៤៦ ក្រាម, ដើមកញ្ឆា ២៤០ ដើម, សារធាតុសង្ស័យគ្រឿងញៀន ២,១៦ ក្រាម ។
- ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន បានចាប់យករួមមាន ម៉ូតូ ២៣ គ្រឿង, ប្រាក់កម្ពុជា ៦៥៩.១០០ រៀល, ប្រាក់អាមេរិក ២៥១ ដុល្លារ ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២ ។

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៧ ដីកា = មនុស្ស ៧ នាក់ (ស្រី១នាក់) ជនជាតិខ្មែរ ។

## ខ. ការត្រួតពិនិត្យ និងគ្រប់គ្រងសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុង ខែឧសភា ឆ្នាំ២០១៤ នេះ មានដូចខាងក្រោម :

- សារធាតុគីមីចម្រុះ សរុបចំនួន ***១.៣៩២.៨៥០*** គ.ក្រ ***៨៥០*** កាឡុង និង ***៧.៥០០*** លីត្រ ក្នុងនោះ សារធាតុគីមីដែលពាក់ព័ន្ធនឹង ៖
  - ✓ តារាងទីIV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ៣៤១.៥០០ គ.ក្រ ២០០ កាឡុង ៤៥០០ លីត្រ
  - ✓ តារាងទីIII នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ២៥០ គ.ក្រ
  - ✓ ប្រកាសរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម[(1)] មាន ១.០៥១.១០០ គ.ក្រ ៦៥០ កាឡុង ៣.០០០ លីត្រ
- វត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ សរុបចំនួន ១៣ គ.ក្រ ៣៥០ ក្រាម ដែលពាក់ព័ន្ធនឹងតារាងឧបសម្ព័ន្ធ III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២) ។

## គ. ការងារកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានធ្វើកោសលវិច័យលើសំណាក

[1] ប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម លេខ ១១០ ឧរថ.សឧក.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងនិងត្រួតពិនិត្យ ការប្រើប្រាស់ នាំចូល នាំចេញ និងចែកចាយសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម

សង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុងខែឧសភា ឆ្នាំ២០១៤ នេះ សរុបចំនួន ២៦ ករណី =២៩ សំណាក ។ ក្នុងនោះ :

- សំណាកវិជ្ជមានសារជាតុញៀន មាន ២៨ សំណាក គឺ :
  មេតំហ្វេតាមីន ICE ១៦ សំណាក = ៥៥,១៧ % មេតំហ្វេតាមីន WY ១២ សំណាក = ៤១,៣៧ %
- សំណាកអវិជ្ជមានសារជាតុញៀន ១ សំណាក = ៣,៤៤ %

## ***២.៣. ការកាត់បន្ថយគ្រោះថ្នាក់ និងការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម***

- ***កម្មវិធីកាត់បន្ថយគ្រោះថ្នាក់***
  - ***ការងារក្នុងប្រទេស***

✓ បានធ្វើបទបង្ហាញស្តីពីការពង្រឹងការឆ្លើយតបមេរោគអេដស៍ / ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ តាមរយៈកម្មវិធីដៃគូសហគមន៍សម្រាប់ប្រជាជនប្រឈមមុខខ្ពស់ តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៖

- **ក្នុងសិក្ខាសាលា ៖**
  - នៅខេត្តព្រះសីហនុ ថ្ងៃទី០៦/៥/២០១៤ មានសិក្ខាកាម ***៥៣*** នាក់
  - នៅខេត្តកំពង់ធំ ថ្ងៃទី០៦/៥/២០១៤ មានសិក្ខាកាម ***៥៤*** នាក់
  - នៅខេត្តតាកែវ ថ្ងៃទី០៩/៥/២០១៤ មានសិក្ខាកាម ***៥៣*** នាក់
  - នៅខេត្តកំពង់ស្ពឺ ថ្ងៃទី០៩/៥/២៩១៤ មានសិក្ខាកាម ***៥៥*** នាក់
- **វគ្គបណ្តុះបណ្តាល ៖**
  - នៅខេត្តកំពង់ធំ ថ្ងៃទី១៩-២០/៥/២០១៤ មានសិក្ខាកាមចូលរួម ***៥៤*** នាក់
  - នៅខេត្តព្រះសីហនុ ថ្ងៃទី២២-២៣/៥/២០១៤ មានសិក្ខាកាម ***៥៣*** នាក់
  - នៅខេត្តតាកែវ ថ្ងៃទី២៦-២៧/៥/២០១៤ មានសិក្ខាកាម ***៥៣*** នាក់
  - នៅខេត្តកំពង់ស្ពឺ ថ្ងៃទី២៩-៣០/៥/២០១៤ មានសិក្ខាកាម ***៥៣*** នាក់

✓ បានធ្វើបទបង្ហាញស្តីពីការពង្រឹងការឆ្លើយតបមេរោគអេដស៍ / ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ តាមរយៈកម្មវិធីដៃគូសហគមន៍សម្រាប់ប្រជាជនប្រឈមមុខខ្ពស់ តាមការអញ្ជើញរបស់គណៈកម្មការសម្របសម្រួលកម្មវិធីអេដស៍ ៖

- **ក្នុងសិក្ខាសាលា ៖**
  - នៅខេត្តរតនគិរី ថ្ងៃទី០៦/៥/២០១៤ មានសិក្ខាកាម ***៦៩*** នាក់
  - នៅខេត្តក្រចេះ ថ្ងៃទី០៨/៥/២០១៤ មានសិក្ខាកាម ***៦៥*** នាក់
  - នៅខេត្តមណ្ឌលគិរី ថ្ងៃទី២០/៥/២០១៤ មានសិក្ខាកាម ***៦៥*** នាក់
  - នៅខេត្តព្រះវិហារ ថ្ងៃទី២៧/៥/២៩១៤ មានសិក្ខាកាម ***៦៤*** នាក់
  - នៅខេត្តឧត្តរមានជ័យ ថ្ងៃទី២៩/៥/២០១៤ មានសិក្ខាកាម ***៧១*** នាក់
- **វគ្គបណ្តុះបណ្តាល ៖**
  - នៅខេត្តក្រចេះ ថ្ងៃទី២២-២៣/៥/២០១៤ មានសិក្ខាកាម ***៤៦*** នាក់

- ✓ បន្តផ្តល់ការអនុញ្ញាតឲ្យអង្គការ ខាន់ណា អនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង នៅរាជធានីភ្នំពេញ ។
- ✓ បានចូលរួមក្នុងកិច្ចប្រជុំសម្របសម្រួលស្តីពី ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀននៅកម្ពុជា (លើកទី២ នៅខេត្តសៀមរាប ថ្ងៃទី២៣/៥/២០១៤) ។
- ✓ បានចូលរួមកិច្ចប្រជុំក្រុមការងារសុខភាពផ្លូវចិត្តអាស៊ាន លើកទី៣ នៅខេត្តសៀមរាប ថ្ងៃទី០៧-០៩/៥/២០១៤ ។
- ✓ បានចូលរួមកិច្ចប្រជុំពិភាក្សាលើយន្តការចំណាយថវិកា ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ដែលជាមូលនិធិរបស់កម្មវិធីជំនួយអូស្ត្រាលី កាលពីថ្ងៃទី០៩/៥/២០១៤ ។
- ✓ បានរៀបចំកិច្ចប្រជុំស្តីពីការងារសម្របសម្រួលកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ នៅសណ្ឋាគារភ្នំពេញ (អ្នកចូលរួម ***៣០*** នាក់) ។

- ***ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន***
  - ✓ បានចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន នៃក្រសួងសុខាភិបាល កាលពីថ្ងៃទី០៥/៥/២០១៤ នៅទីស្តីការក្រសួងសុខាភិបាល ។
  - ✓ ជំរុញការអនុវត្តកម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍តាមប្រព័ន្ធសុខាភិបាល នៅទូទាំងរាជធានី-ខេត្ត ទាំង ២៥ ។
  - ✓ បានរៀបចំកិច្ចប្រជុំអន្តរក្រសួងពាក់ព័ន្ធ ដើម្បីពិភាក្សាលើការងារកាត់បន្ថយតម្រូវការ និងគ្រោះថ្នាក់ពាក់ព័ន្ធនឹងគ្រឿងញៀន និងការត្រៀមបញ្ជូនមន្ត្រីទៅទទួលការបណ្តុះបណ្តាលលើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅសាធារណរដ្ឋសង្គមវៀតណាម ។
  - ✓ បានបន្តរៀបចំរបាយការណ៍ស្តីពី កម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ជាមូលដ្ឋាននៅកម្ពុជា តាមការស្នើសុំរបស់ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC) ។

## ២.៤. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់

### ការងារក្នុងប្រទេស

- បានចុះត្រួតពិនិត្យទីតាំង សម្ភារៈបច្ចេកទេសសម្រាប់សិក្សាតាមប្រព័ន្ធកុំព្យូទ័រ (CBT) និងប្រមូលរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-វៀតណាម នៅការិយាល័យទំនាក់ទំនងព្រំដែន ភ្នំដិន ខេត្តតាកែវ (២០-២១/៥/២០១៤), នៅការិយល័យទំនាក់ទំនងព្រំដែន បាវិត ខេត្តស្វាយរៀង (២២-២៣/៥/២០១៤) ។
- ចូលរួមធ្វើបទឧទ្ទេសនាមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះបទល្មើសពិសេស ចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី១៩-២១ ខែឧសភា ឆ្នាំ២០១៤ ដែលមានសមាសភាពចូលរួមជា ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ សរុបចំនួន ***៦០*** រូប ។
- បានប្រជុំពិភាក្សាលើការងារបច្ចេកទេស ជាមួយតំណាងក្រសួងការពារជាតិដើម្បីបន្តរៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (០៨/៥/២០១៤) ។

- បានសហការជាមួយអ្នកសម្របសម្រួលគម្រោងរបស់អង្គការ UNODC រៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់គម្រោង PATROL លើកទី៦ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ។

***ការងារក្រៅប្រទេស***

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមសិក្ខាសាលាស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋានអន្តរជាតិ នៃបណ្តាប្រទេសអាស៊ាន លើកទី៤ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន (២១-២២/៥/២០១៤) ។
- បានចាត់បញ្ជូនមន្ត្រីជំនាញ ០១ រូប ទៅសិក្សាវគ្គបំប៉នជំនាញការងារដឹកនាំ សម្រាប់ថ្នាក់ នាយកដ្ឋាន ស្នងការ និង ការិយាល័យ លើកទី២៩ រយៈបីខែ នៅសាលាជាន់ខ្ពស់សន្តិសុខប្រជាជន២ ភាគខាងត្បូង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។
- បានចាត់មន្ត្រីជំនាញទៅទទួលវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន រវាង កម្ពុជា-ថៃ (នៅប្រទេសថៃ ១៩-២៣/៥/២០១៤) ។

ដោយឡែក មន្ត្រីនៃការិយាល័យទំនាក់ទំនងព្រំដែន (BLO) ច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានទៅចូលរួមប្រជុំនៅស្រុកអារញ្ញ ជាមួយមន្ត្រីនៃការិយាល័យទំនាក់ទំនងព្រំដែន ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ (ថៃ) កាលពីថ្ងៃទី២១/៥/២០១៤ ដើម្បីផ្លាស់ប្តូរព័ត៌មានគ្រឿងញៀន និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ (ខាងភាគីកម្ពុជាមានមន្ត្រីពាក់ព័ន្ធចូលរួម ១៦ រូប)

### ***២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជិតខាង***

- បានសម្របសម្រួលជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ដើម្បីចាត់បញ្ជូនមន្ត្រីជំនាញទៅទទួលវគ្គបណ្តុះបណ្តាលពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន (នៅប្រទេសថៃ ១៩-២៣/៥/២០១៤) ។

### ***២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ***

- បានសម្របសម្រួលជូននាយកដ្ឋានជំនាញ បានទៅចូលរួមសិក្ខាសាលាស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋានអន្តរជាតិ នៃបណ្តាប្រទេសអាស៊ាន លើកទី៤ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន (២១-២២/៥/២០១៤) ។
- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់ នៃបណ្តាប្រទេសហត្ថលេខី ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀននៅក្នុងមហាអនុតំបន់ទន្លេមេគង្គ កាលពីថ្ងៃទី២៧-៣០ ខែឧសភា ឆ្នាំ២០១៤ នៅទីក្រុងប៉េកាំង ប្រទេសចិន ។

### ***២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ***

ដើម្បីពង្រឹង និងពង្រីកលទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យ ឲ្យមានប្រសិទ្ធភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តជំរុញការរៀបចំអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. ចូលរួមក្នុងកិច្ចប្រជុំអ្នកពាក់ព័ន្ធដើម្បីពិភាក្សាលើប្រធានបទស្តីពី គោលនយោបាយគ្រឿងស្រវឹង តាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព (ថ្ងៃទី៣០/៥/២០១៤) ។

១.២. ស្នើទៅក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ CTN និង CNC ស្តីពី ការទទួលខុសត្រូវលើការងារអប់រំបង្ការ និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (១៨/៦/២០១៤) ។

១.៣. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន និងការបង្ការទប់ស្កាត់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផល ស៊ីហ្សា និង បារីអេឡិចត្រូនិច ទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម និងវេទិកានានា នៅតាមរាជធានី-ខេត្ត ទូទាំងប្រទេស ។

១.៤. បន្តការតាមដាន ត្រួតពិនិត្យលើការអនុវត្តកម្មវិធីអប់រំពីបញ្ហាគ្រឿងញៀន និងគ្រឿងស្រវឹង ដែលអនុវត្តដោយសមាគមយុវជនខ្មែរ នៅតាមវិទ្យាល័យ-អនុវិទ្យាល័យ និងនៅតាមសហគមន៍ ក្នុងរាជធានីភ្នំពេញ, ខេត្តបាត់ដំបង, បន្ទាយមានជ័យ និងខេត្តសៀមរាប ។

១.៥. បន្តចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន នៃក្រសួងសុខាភិបាល ។

១.៦. បន្តការរៀបចំកម្មវិធីប្រឡងប្រណាំងការគូរគំនូរក្រោមប្រធានបទ យើងរួបរួមគ្នាប្រឆាំងគ្រឿងញៀន ។

១.៧. រៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១៤ ។

១.៨. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ។

១.៩. បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និងនៅតាមសហគមន៍ ។

### ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយមន្ទីរប្រឆាំងគ្រឿងញៀន, ការិយាល័យប្រឆាំងគ្រឿងញៀនរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងការស្រាវជ្រាវរកខ្សែរយៈទាក់ទង ដែលនៅសេសសល់ពាក់ព័ន្ធនឹងករណីធំៗដែលបង្ក្រាបបានកន្លងមក ។

២.២. ចាត់វិធានការដោះស្រាយចំពោះសារធាតុគីមី ចំនួន ១៨.៩០០ គ.ក្រ ដែលបានចុះទៅពិនិត្យដល់ទីកន្លែងរក្សាទុក នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

២.៣. បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. បន្តការចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ នៅខេត្តតាកែវ (២៦-២៧/៥/២០១៤) និង នៅខេត្តកំពង់ស្ពឺ (២៩-៣០/៥/២០១៤) តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

៣.២. បន្តចូលរួមតាមការអញ្ជើញរបស់គណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីធ្វើបទឧទ្ទេសនាមនៅក្នុង ៖

- ✓ សិក្ខាសាលា ពង្រឹងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ តាមរយៈកម្មវិធីដៃគូសហគមន៍ នៅខេត្តព្រះវិហារ ថ្ងៃទី២៧/៥/២០១៤, នៅខេត្តឧត្តរមានជ័យ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ។
- ✓ វគ្គបណ្តុះបណ្តាល ពង្រឹងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ តាមរយៈដៃគូសហគមន៍ នៅខេត្តព្រះវិហារ ថ្ងៃទី០៥-០៦/៦/ ២០១៤, នៅខេត្តឧត្តរមានជ័យ ថ្ងៃទី១៦-១៧/៦/២០១៤, នៅខេត្តមណ្ឌលគិរី ថ្ងៃទី២៤-២៦/៦/ ២០១៤ ។

៣.៣. ត្រៀមចូលរួមក្នុងកិច្ចប្រជុំអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាលើប្រធានបទស្តីពី គោលនយោបាយគ្រឿងស្រវឹង តាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (ថ្ងៃទី៣០/៥/២០១៤) ។

៣.៤. បន្តជំរុញការអនុវត្តកម្មវិធីផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍តាមប្រព័ន្ធសុខាភិបាល នៅទូទាំងរាជធានី-ខេត្ត ទាំង ២៥ ។

៣.៥. បន្តជំរុញក្រសួងសុខាភិបាល ក្នុងការរៀបចំបញ្ជីឈ្មោះកន្លែងផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន (CBTx) នៅតាមរាជធានី-ខេត្ត និងជំរុញការផ្តល់សេវានេះ នៅរាជធានីភ្នំពេញ ។

៣.៦. ជំរុញក្រសួងសុខាភិបាល ក្នុងការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

៣.៧. រៀបចំកែសម្រួលសមាសភាពគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ ។

៣.៨. បន្តសហការជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការកែសម្រួលឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ស្តីពី យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

## ៤. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តច្បាប់

៤.១. បន្តចុះត្រួតពិនិត្យទីតាំង សម្ភារៈបច្ចេកទេសសម្រាប់ការសិក្សាដោយប្រព័ន្ធកុំព្យូទ័រ នៅការិយាល័យទំនាក់ទំនងព្រំដែន ច្រកត្រពាំងផ្លុង ខេត្តកំពង់ចាម (២៦-២៧/៥/២០១៤), ការិយាល័យទំនាក់ទំនងព្រំដែន ច្រកត្រពាំងគ្រៀល និង កោះឈើទាលធំ ខេត្តស្ទឹងត្រែង (២៨-២៩/៥/២០១៤), ការិយាល័យទំនាក់ទំនងព្រំដែន ច្រកកំពង់ស្រឡៅ ខេត្តព្រះវិហារ (៣០-៣១/៥/២០១៤) ។

៤.២. រៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់គម្រោង PATROL លើកទី៦ (ថ្ងៃទី១០/៦/២០១៤ នៅសណ្ឋាគារSofitel Phnom Peng Phokeethra ) និងពិធីប្រគល់-ទទួលសម្ភារៈការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

៤.៣. ត្រៀមដឹកនាំប្រតិភូរបស់អគ្គលេខាធិការដ្ឋាន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ។

៤.៤. រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់នានា នៅតាមខ្សែបន្ទាត់ព្រំដែន ។

៤.៥. បន្តរៀបចំបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ តាមម៉ាស៊ីនកុំព្យូទ័រ (CBT) ។

៤.៦. ត្រោមរៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមច្រកអាកាសយានដ្ឋាន អន្តរជាតិ នៃបណ្តាប្រទេសអាស៊ាន ។

៤.៧. រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលក្រសួងការពារជាតិ ចំនួន ៧៥ រូប នៅថ្ងៃទី១០/០៦/ ២០១៤ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. ត្រៀមទៅចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើការបង្កើត ASEAN-NARCO នៅទីក្រុងបាងកក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ ។

៥.២. ត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-វៀតណាម លើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀនតាមតំបន់ព្រំដែន (BLO) ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤-១៧ ខែកក្កដា ឆ្នាំ២០១៤ ។

៥.៣. ជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ / កម្ពុជា-វៀតណាម / កម្ពុជា-ឡាវ ។

៥.៤. រៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅប្រទេសវៀតណាម និង ឡាវ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និង អន្តរជាតិ

៦.១. ត្រៀមជួបពិភាក្សាការងារជាមួយអ្នកវាយតម្លៃឯករាជ្យគម្រោង PTROL នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ។

៦.២. ត្រៀមរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាយោបល់គម្រោង (C-PAC) និងរៀបចំពិធីប្រគល់-ទទួលសម្ភារៈការិ-យាល័យទំនាក់ទំនងព្រំដែន នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ ។

៦.៣. ត្រៀមសហការជាមួយអតីតអ្នកជំនាញការវិភាគគ្រឿងញៀនស្ម័គ្រចិត្តជប៉ុន ដែលអញ្ជើញមកបណ្តុះបណ្តាលបច្ចេកទេសវិភាគគ្រឿងញៀន ដល់មន្ត្រីបច្ចេកទេសនៅមន្ទីរពិសោធន៍គ្រឿងញៀន ។

៦.៤. ចូលរួមកិច្ចប្រជុំគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់ស្តីពីបញ្ហាគ្រឿងញៀន (ធ្វើនៅទីក្រុងប៉េកាំង ថ្ងៃទី២៧-៣០ ខែឧសភា ឆ្នាំ២០១៤) និងដំណើរទស្សនកិច្ចសិក្សាគម្រោង Sunshine ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមសហគមន៍ (ធ្វើនៅទីក្រុងហ្គុយយ៉ាង ប្រទេសចិន ថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០១៤) ។

៦.៥. ត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំនានា ក៏ដូចជាត្រៀមទៅចូលរួមរាល់កិច្ចប្រជុំ សន្និសីទ សិក្ខាសាលា ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ។

៦.៦. ត្រៀមចាត់បញ្ជូនមន្ត្រីជំនាញ ០១ រូប របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ទៅចូលរួមជាសមាជិក នៃមជ្ឈមណ្ឌលព័ត៌មាននិងសហប្រតិបត្តិការ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រចាំតំបន់ អាស៊ី និងប៉ាស៊ីហ្វិក ដែលមានស្នាក់នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. បន្តរៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.២. ត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលរបស់ការសិក្សា ការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀនថ្នាក់ជាតិ ការអង្កេតលើឥរិយាបថប្រឈមចំពោះមេរោគអេដស៍ និងប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀននៅប្រទេសកម្ពុជា ឆ្នាំ២០១២ ។

៧.៣. រៀបចំវគ្គបណ្តុះបណ្តាលពីអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៃក្រសួងសមាជិក របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៤. រៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់ មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ នៅតាមរាជធានី-ខេត្ត ។

៧.៥. ត្រៀមរៀបចំកិច្ចប្រជុំ គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជាឡាវ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ នៅខេត្តរតនគិរី ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣
  "ដើម្បីជូនជ្រាប"
- ក្រសួង សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋាន សរុប ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីមុខការ"
- ឯកសារ